គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក **ធុន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុខ សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គហេរញ្ញិក
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **ស៊ីន សែត**
Mr. SEN Set

# របាយការណ៍លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោត
# ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្ត កំពង់ស្ពឺ

*ភ្នំពេញ, ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៩*

គណៈកម្មាធិការខុមហ្វ្រែល ដោយមានកិច្ចសហការជាមួយអង្គការ សហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (padek) បានរៀបចំសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ស្ពឺ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩។ សិក្ខាសាលានេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍ [១] នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នក-តំណាងរាស្រ្ត ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

នៅក្នុងសិក្ខាសាលានេះ មានអ្នកចូលរួមចំនួន ៨៨នាក់ ដែលតំណាងឱ្យសហគមន៍នេសាទ ព្រៃឈើ ដីធ្លី ... សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងខេត្ត អាជីវករ/ពាណិជ្ជករ មន្រ្តីរាជការ សិស្ស/ និស្សិត កសិករ ដែលមកពីស្រុកទាំង៨ ក្នុងខេត្តកំពង់ស្ពឺ។ ក្នុងនោះសិក្ខាកាមចូលរួមជាស្រ្តីមានចំនួន ៣៤% (ស្មើនឹង៣០ នាក់)។

---

[២] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

សិក្ខាសាលានេះក៏មានការចូលរួមពីអាជ្ញាធរខេត្ត និងអ្នកតំណាងរាស្ត្រក្នុងមណ្ឌលកំពង់ស្ពឺឯកឧត្តម លី សុន និងឯកឧត្តម នុត រំដួលផងដែរ ។ ឯកឧត្តមតំណាងរាស្ត្រទាំងពីររូបបានទទួលយកលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនេះ ហើយបានមានប្រសាសន៍ថា ខិតខំជួយអន្តរាគមន៍ និងដោះស្រាយ ។

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែលបានមានប្រសាសន៍ថា "*លក្ខខណ្ឌសន្ទស្សន៍នេះនឹងក្លាយជាឯកសារដ៏សំខាន់សម្រាប់ម្ចាស់ឆ្នោតហើយក៏បំពេញបន្ថែមទៅលើកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ ម្ចាស់ឆ្នោតនឹងវាយតម្លៃការអនុវត្តរបស់មន្ត្រីជាប់ឆ្នោត (តំណាងរាស្ត្រ និងរាជរដ្ឋាភិបាល) ចំពោះកម្មវិធីនយោបាយតាមរយៈលទ្ធផលបានមកពីការអនុវត្តលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនេះ ។ ហើយម្ចាស់ឆ្នោតនឹងពិចារណាលទ្ធផលនៃការវាយតម្លៃនេះដើម្បីធ្វើការសម្រេចចិត្តធ្វើការបោះឆ្នោតខាងមុខ*"។

សិក្ខាកាមម្ចាស់ឆ្នោតក្នុងខេត្តកំពង់ស្ពឺបានកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពចំនួន ២៤ ហើយបានបោះឆ្នោតជ្រើសរើសលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពសំខាន់ជាងគេចំនួន ១០ ក្នុងចំណោម ២៤ ដើម្បីបញ្ជូនទៅរាជរដ្ឋាភិបាល សមាជិកសភា អាជ្ញាធរខេត្ត ( ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តនាពេលខាងមុខ) ។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកំពង់ស្ពឺរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត កំពង់ស្ពឺ** |
|---|
| ១) សូមជួយទប់ស្កាត់ បង្កាការកាប់បំផ្លាញព្រៃឈើនៅស្រុក គងពិសី ឱរ៉ាល់ ភ្នំស្រួច ថ្ពង [ឱ្យបាន ១០០%[២] ] ចាប់ពីត្រឹមឆ្នាំ ២០១០ និង សុំបង្កើតព្រៃសហគមន៍នៅតំបន់ភ្នំព្រះ ឃុំ យាអង្គ ស្រុកថ្ពង ចំនួន ៣.៨៧៩ ហិកតា នៅឆ្នាំ ២០០៩ និងសុំអោយរដ្ឋបាលព្រៃឈើជួយ រៀបចំសំណុំឯកសារ និងទទួលស្គាល់សហគមន៍ព្រៃឈើនៅឃុំ ទ័ពមាន ស្រុកថ្ពង ។ |
| ២) សុំជួយដោះស្រាយដីសម្បទានសង្គមកិច្ចនៅឃុំអមលាំង ៨ ភូមិ ១.៨៥០ហិកតា នៅឃុំយាអង្គ ៣ភូមិ ១.៤០០ហិកតា នៅឃុំមហាសាំង និងតាំងស្យា នៅតំបន់ អា សេ អូ ផ្ទៃដីស្រែ ៤២៩,២៧ហិកតា ដីចំការ ១១៥,៤៧ហិកតា(១០សហគមន៍) និងសុំដោះស្រាយវិវាទដីនៅភូមិព្រីង ឃុំ រលាំងចក ស្រុកសំរោងទង ។ សុំផ្តល់ប្លង់កម្មសិទ្ធដីនៅឃុំតាសាល់ ស្រុកឱរ៉ាល់ ។ |
| ៣) ផ្តល់ថ្នាំវ៉ាក់សាំង បង្កាជំងឺសត្វអោយបានគ្រប់គ្រាន់មួយឆ្នាំម្តង (ឬតាមជំនាញបច្ចេកទេស) និងគ្រប់តំបន់ និងសូមត្រួតពិនិត្យទីសត្តឃាតជារៀងរាល់ថ្ងៃអោយបានដិតដល់ចាប់ពីខែ មេសា ឆ្នាំ ២០០៩ តទៅ ។ |
| ៤) លុបបំបាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ( ប្រដាប់ឆក់ត្រី) អោយមានប្រសិទ្ធភាពមួយរយភាគរយនៅក្នុង ឆ្នាំ ២០១០ និងលុបបំបាត់ការប្រមាញ់ និងបំពុលសត្វព្រៃអោយបានមួយរយភាគរយ ចាប់ពីឆ្នាំ ២០១០ ។ |
| ៥) បញ្ហាអនាម័យ : ប្រមូលសំរាមក្នុងផ្សារកំពង់ស្ពឺ និងក្នុងទីកស្ទឹងឱ្យស្អាត និងសណ្តាប់ធ្នាប់នៅក្នុងផ្សារឱ្យហើយ ឆ្នាំ ២០០៩ តទៅ ។ |
| ៦) សុំឱ្យរដ្ឋជួយទិញកសិផលនៅពេលគ្មានទីផ្សារសម្រាប់ផលិតផលកសិកម្ម ឬពេលដែលតម្លៃកសិផលធ្លាក់ចុះ ដោយរដ្ឋត្រូវឱ្យតម្លៃថ្លៃជាងទីផ្សារ ។ |

[២] មានការពន្យល់បន្ថែមឱ្យកាន់តែច្បាស់ពីសិក្ខាកាមមួយចំនួនបន្ទាប់ពីសិក្ខាសាលា

| |
|---|
| ៧) តម្លើងប្រាក់បៀវត្សដល់មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន និងគ្រូពេទ្យពី ១០០ ដុល្លារ ឡើងទៅ ចាប់ពីឆ្នាំ ២០១០ និងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូតាមក៏រិត និងមុខជំនាញម្នាក់ៗឱ្យបានម្តងក្នុងមួយឆ្នាំនៅគ្រប់ភូមិសិក្សា ចាប់ពីឆ្នាំ ២០១០ ។ |
| ៨) នៅគ្រប់មណ្ឌលសុខភាពត្រូវមានថ្នាំគ្រប់គ្រាន់ និងមានបុគ្គលិកជំនាញប្រចាំការគ្រប់ម៉ោងចាប់ពីចុងឆ្នាំ ២០០៩ និង បង្កើនការព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ ។ |
| ៩) សុំឱ្យច្បាប់ប្រឆាំងអំពើពុករលួយចេញឱ្យបានឆាប់យ៉ាងយូរដើមឆ្នាំ ២០១០ ។ |
| ១០) សុំឱ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ពីមូលដ្ឋាន រហូតដល់ថ្នាក់ខេត្តសុំឱ្យដោះស្រាយទំនាស់ដីធ្លីចាប់ពីខែមេសា ឆ្នាំ២០០៩ ជាពិសេសដី អា សេ អូ ដោះស្រាយឱ្យចប់នៅក្នុងឆ្នាំ ២០០៩ និងសុំឱ្យមានច្បាប់ផ្តន្ទាទោសដល់តុលាការ មន្ត្រីរាជការ យោធា ប៉ូលីស ប៉េអឹម នៅទូទាំងខេត្តកំពង់ស្ពឺ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក ពីជនល្មើស ។ |

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **កុយ ចំនួនដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិន្ទុរ្យ** អ្នកសម្របសម្រួលស្តីទីផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦